ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០១២ សហវ-អពន

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០០៩

# សេចក្តីជូនដំណឹង

## ស្តីពី

## វិធានការបំបាត់ការលួចបន្លំបោះពុម្ព ការធ្វើអាជីវកម្មជួញដូរ និង ការប្រើប្រាស់ប័ណ្ណក្លែងក្លាយសំរាប់បង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ឆ្នាំ២០០៩

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានកិត្តិយសជំរាបជូនសាធារណជនទាំងអស់មេត្តាជ្រាបថា កន្លងមកនេះ មានជនខិលខូចមួយចំនួនបានលួចបន្លំបោះពុម្ពលក់ និងប្រើប្រាស់នូវប័ណ្ណក្លែងក្លាយសំរាប់បង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទឆ្នាំ២០០៩ នៅលើទីផ្សារក្នុងរាជធានីភ្នំពេញ និង ខេត្ត នានា ។

ក្នុងគោលបំណងទប់ស្កាត់អំពើល្មើសច្បាប់ខាងលើនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការបដិសេធមិនទទួលស្គាល់ប័ណ្ណក្លែងក្លាយលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះនេះឡើយ ។ ទន្ទឹមនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងចាត់វិធានការតាមច្បាប់រួមជាមួយក្រសួងមានសមត្ថកិច្ច ដើម្បីចាប់ឃាត់ទុកជនទាំងឡាយណាដែលបានលួចបន្លំបោះពុម្ព ធ្វើអាជីវកម្មលក់ដូរ និងប្រើប្រាស់ប័ណ្ណក្លែងក្លាយទាំងនេះ យកមកផ្តន្ទាទោសតាមមាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ ដែលបានចែងថា " ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាដែលបានប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់នេះ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០រៀល (ប្រាំលានរៀល) ដល់ ១០.០០០.០០០រៀល(ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ " ។

ចាប់ពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩ តទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យផាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងឡាយណាដែលមិនបានបង់ពន្ធសំរាប់ឆ្នាំ២០០៩ ។ ចំពោះរថយន្ត ម្ចាស់យានយន្តត្រូវយកបង្កាន់ដៃបង់ពន្ធឆ្នាំ២០០៩ ដាក់តាមរថយន្តរបស់ខ្លួន ដើម្បីបង្ហាញជូនមន្ត្រីដែលមានសមត្ថកិច្ចត្រួតពិនិត្យនៅតាមចំណុចដៅមួយចំនួន ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាប និងចូលរួមបំបាត់អំពើល្មើសច្បាប់កុំបីខាន ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com